# ការសំភាស៍របស់អ៊ុំស្រី ឡឹក វណ្ណា

កៈ អ្នកដែលធ្វើការសំភាស៍គេ អ៊ុំ កន្និកា ខៈ អ្នកដែលត្រូវអោយគេសំភាស៍គេ ឡឹក វណ្ណា

គៈ អ្នកដែលបានចូលរូមក្នុងការសំភាសន៍ តូច

នាងខ្ញុំឈ្មោះ អ៊ុំ កន្និកា
ដែលមកពីខាងសាលាប៊ីវ៉ាយយ៉ូដើម្បីធ្វើនូវគម្រោងរក្សាពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាហើយពូកយើងធ្វើការរីខតសម្លេងមួយនេះនៅក្នុងថ្ងៃទីម្ភៃបួន
ខែមួយឆ្នាំពីរពាន់ដប់ប្រាំបីផងដែរនៅម្តុំខណ្ឌចំការមនយើងនិងជួបជាមួយបងស្រីម្នាក់ដែលគាត់និងចែកចាយអំពីជីវប្រវត្តិរបស់គាត់ផងដែរហើយនៅពេលនេះយើងនិងទៅជួបជាមួយគាត់ទាំងអស់គ្នានាងខ្ញុំឈ្មោះអ៊ុំ កន្និកា ដែលមកពីខាងសាលា "ប៊ីវ៉ាយយ៉ូ"
(BYU)ដើម្បីធ្វើនូវគម្រោងរក្សាពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាហើយពូកយើងធ្វើការរីខតសម្លេងមួយនេះនៅក្នុងថ្ងៃទីម្ភៃបួន
ខែមួយឆ្នាំពីរពាន់ដប់ប្រាំបីផងដែរនៅម្តុំខណ្ឌចំការមនយើងនិងជួបជាមួយបងស្រីម្នាក់ដែលគាត់និងចែកចាយអំពីជីវប្រវត្តិរបស់គាត់ផងដែរហើយនៅពេលនេះយើងនិងទៅជួបជាមួយគាត់ទាំងអស់គ្នា។

កៈ ជំរាបសួរអ៊ុំស្រី!

ខៈ ចាំ ចាំជំរាបសួរក្មួយ...។

កៈ តើអ៊ុំស្រីមានឈ្មោះអ្វីដែល?

ខៈ ឈ្មោះ ឡឹក វណ្ណា។

កៈ ចុះអ៊ុំស្រីមានអាយុប៉ុន្មានហើយ?

ខៈ ញុំមហាសិបប្រាំហើយអូន។

កៈ អ៊ុំស្រី! ដូចជាអ៊ុំស្រីមានឈ្មោះកាលពីនៅក្មេងទេ?

ខ៖  ចា៎ ឈ្មោះនិងតាំងពីនៅក្មេងតាស់អូន។

ក៖ ប្រើឈ្មោះនេះតាំងពីនៅក្មេង ...ចុះដូចជារហ័សនាមដែលគេដាក់អោយតាំងពីនៅក្មេងមានទេអ៊ុំស្រី?

ខ៖មានតាអូន...!

ក៖ឈ្មោះអីដែល?

ខ៖អឺឈ្មោះតាំងពីតូចមកម្តាយចេះតាហៅមីអូនៗចឹងទៅ...

ចា៎..តែបើក្នុងបញ្ជីជាតិឈ្មោះវណ្ណាចឹងទៅ។

ក៖ដូចជាអ៊ុំស្រីកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ឆ្នាំមួយពាន់ប្រាំបួនរយហុកពីរ។

ក៖ចា៎..ចុះចាំថ្ងៃខែច្បាស់ទេ?

ខ៖អូ អត់ចាំទេ។

ក៖ចុះឆ្នាំច័ន្ទគតិដូចជាឆ្នាំជូតឆ្លូវខាលអីអញ្ចឹងអ្នាស?

ខ៖អ៎...ខាល...!

ក៖ចា៎ ឆ្នាំខាលចា៎ស ចុះទីកន្លែងកំណើតវិញអ៊ុំស្រី?

ខ៖ទីកំណើតរបស់ញ៉ុមនៅអើយខាង ឈ្លូងក្រចេះហា៎សអូន។

ក៖អ៎..នៅខាងខេត្តក្រចេះវិញ?ចឹង អ៊ុំស្រីប្រើរយៈពេលប៉ុន្មានហើយដែលមករស់នៅទីក្រុងភ្នំពេញនេះ?

ខ៖  មករសនៅទីក្រុងភ្នំពេញនេះញ៉ុមមករស់នៅតាំងពីមួយពាន់ប្រាំបួនរយចិតសិបប្រាំបួន។

ក៖  អ៎ តាំងពីមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនអ៊ូរៀងយូ៉ហើយដែល?

ខ៖  ចា៎ យូ៉ហើយ....។

កៈចុះចំណែកក្រុមគ្រួសាររបស់អ៊ុំវិញ
ដូចជាបងប្អូនរបស់បងវិញតើមានចំនួនប៉ុន្មាននាក់ដែលអ៊ុំ?

ខៈ ញ៉ុមប្រាំនាក់តែរាល់ថ្ងៃនៅសល់តែបីនាក់ទេ។

កៈ ពីរនាក់ទៀតគាត់ទៅណាដែលអ៊ុំ?

ខៈ គាត់ស្លាប់អស់ហើយ..។

កៈ
តើអ៊ុំអាចប្រាប់ឈ្មោះនិងអាយុរបស់បងច្បងគួបផ្សំជាមួយបងប្អូនដែលបានស្លាប់ទៅបានទេ
ដូចជាបងច្បងតើមានឈ្មោះអីហើយអាយុប៉ុន្មានដែលអ៊ុំ?

ខៈ ញ៉ុមបងគេអូន....!

កៈ ហើយចុះបងប្អូនបន្ទាប់ទៀត?

ខៈ បងប្អូនបន្ទាប់ទៀតគេអាយុសែសិបជាងហើយអូន។

កៈ សែសិបជាងហើយ...! ចុះតើគាត់មានឈ្មោះអីដែល?

ខៈ គាត់ឈ្មោះសោភា។

កៈ គាត់ឈ្មោះសោភាហើយចុះបងប្អូនបន្ទាប់ទៀត?

ខៈ បងប្អូនបន្ទាប់ទៀតឡឹក សូដានិងស្លាប់។

កៈ ចាំចុះបន្ទាប់ទៀត?

ខៈ មួយទៀតឈ្មោះឡឹកសាខាស្លាប់ដែលហើយមួយទៀតឡឹកមុនថានិងនៅចាំ។

កៈ គាត់មានអាយុប៉ុន្មានហើយ?

ខៈ អាយុសាមជាង។

កៈ ចាំ....!

ខ៖ អេស សែហើយនេស..... តូច?

គ៖ ប្រហែលជាសែសិបហើយ។

ខ៖ និងហើយសែហើយអត់សូវចាំដែល។

ក៖ ចុះបន្ទាប់ទៀត..!?

ខ៖ អស់ហើយអូន!

ក៖ ចាំ ដូចជាតើបងស្រីមានចៅប៉ុន្មានហើយកូនៗអ៊ុំការហើយឬនៅមានចៅប៉ុន្មាននាក់?

ខ៖ ញ៉ុមរាល់ថ្ងៃចៅនៅរាល់ថ្ងៃមានបីនាក់។

ក៖ អូ..! អ៊ុំមានចៅបីនាក់ហើយអញ្ចឹងចុះអ៊ុំស្រីមានកូនប៉ុន្មាននាក់ដែល?

ខ៖ កូនបួននាក់អូន។

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែល?

ខ៖ ស្រីពីរប្រុសពីរ។

ក៖ អូ ដូចជាម៉ាក់ញ៉ុមដែល?

ក៖ ហាសហាសហា...! អឺម..ចុះកូនច្បងមានឈ្មោះអ្វីដែល?

ខ៖ ឈ្មោះជុំវត្ថធីអូន។

ក៖ គាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់អាយុសាមសិបប្រាំពីរ។

ក៖ គាត់...! សុំទោសគាត់មានមុខរបរអ្វីដែល?

ខ៖ មុខរបរលក់របស់ហូបចុក

ក៖ គាត់លក់ចាប់ហួយមែន?

ខ៖ អត់តេសគាត់លក់គ្រឿងក្លែម គ្រឿងអាហារ

ក៖ ចុះកូនបន្ទាប់ទៀត?

ខ៖ កូនបន្ទាប់ទៀតគាត់ធ្វើការ

ក៖ ធ្វើការផ្នែកអីគេដែល?

ខ៖ គាត់ធ្វើផ្នែកជាចុងភៅ

ក៖ គាត់មានឈ្មោះអីហើយមានអាយុប៉ុន្មានដែលអ៊ំ?

ខ៖ អាយុសាមសិបប្រាំឆ្នាំ

ក៖ គាត់មានឈ្មោះអ្វីដែល?

ខ៖ ឈ្មោះជុំ រដ្ឋា..!

ក៖ ចុះកូនបន្ទាប់កូនបន្ទាប់ទៀតឈ្មោះអី

ខ៖ ឈ្មោះជុំសារ៉ាត់...!

ក៖ គាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់មានអាយុសាមសិបប្រាំហើយអូន

ក៖ ចាំអាយុសាមប្រាំ ចុះគាត់មានមុខរបរអ្វីដែរ?

ខ៖ អូន! គាត់ធ្វើការនៅបារិត

ក៖ អំគាត់ធ្វើការនៅបារិត ចុះកូនបន្ទាប់ទៀត?

ឈ្មោះជុំសារ៉ាក់អាយុសាមសិបបីឆ្នាំហើយធ្វើការនៅបារិតដែរ

ក៖ ចាំ នៅក្នុងបន្ទុកដែលចៅរស់នៅជាមួយអ៊ុំស្រីមានប៉ុន្មាននាក់ដែល?

ខ៖ មានតាពីរនាក់អ្នេស

ក៖  ចាំ....

ក៖  ចឹង គាត់មានគ្រួសារហើយនៅ?

ខ៖      មាន....គ្រួសារមានអស់ហើយប៉ុន្តែកូនរាល់ថ្ងៃនៅជាមួយម៉ែឪវាដូចថាគ្នាមេម៉ាយអ្នាស ចាំៗនៅតាពីនាក់ទេតែខ្ញុំមេម៉ាយទាំងអស់អត់មានគ្រួសារ...

ក៖ ដូចជាសូមអោយអ៊ុំស្រីប្រាប់ពួកយើងពីគូស្រករបស់ពួកគាត់ដូចថាកូនមួយមានគូស្រករ ឈ្មោះអីចឹងអ្នាស?

ខ៖  ភ្លេចឈ្មោះពេញហើយ...

ក៖អាចប្រាប់ឈ្មោះធម្មតាក៏បានដែលចាំ...?

ខ៖  ជាសុផាន់រិទ្ធ ហៅឈ្មោះរិទ្ធ

ក៖  ចាំ....

ខ៖ហើយវាក៏បានបែកបាក់គ្នាទៅតាំងពីកូននៅតូចៗម៉ោរហូតទល់តែកូនអាយុដប់ប្រាំពីរឆ្នាំ ហើយ

ក៖  ចុះកូនបន្ទាប់ទៀត?

ខ៖ បន្ទាប់ទៀតក៏បែកគ្នាដែលបែកគ្នាតាំងពីកូនអាយុមួយឆ្នាំដល់ឥលូវកូនអាយុដប់មួយឆ្នាំហើយ បែកគ្នា ឈ្មោះជុំរដ្ឋាគាត់ស្រីអ្នាស់

ក៖  ហើយកូនបន្ទាប់ទៀត?

ខ៖  កូនបន្ទាប់ទៀតឈ្មោះជុំសារ៉ាត់ជុំសារ៉ាត់និងធ្វើការនៅបារិតនិង

ក៖  ចាំ គូរបស់គាត់?

ខ៖  គូរបស់គាត់និងក៏បែកគ្នាហើយដែល

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ ឈ្មោះកូនញ៉ុមអ្ហីក៏ឈ្មោះប្រពន្ធ

ក៖ ឈ្មោះប្រពន្ធគាត់...?

ខ៖ ឈ្មោះសាវរី...

ក៖ ចាំ...

ខ៖ សុទ្ធតាបែកគ្នា ....

ក៖ ចុះមួយទៀតអ្ហួស...?

ខ៖ មួយទៀតឈ្មោះ ជុំសារ៉ាត់

ក៖ ចុះគូស្រករបស់គាត់?

ខ៖ គូរបស់គាត់ណោក..ឈ្មោះស្រីនុចនិងគេនៅខេត្តនិងគេនៅជុំគ្នា

ក៖ ចុះចៅរបស់អ៊ុំស្រី ស្រីប៉ុន្មានប្រុសប៉ុន្មាន...?

ខ៖ ញ៉ុមមើលស្រីបីហើយចៅបួននាក់

ក៖ ចៅបួន...ស្រីប៉ុន្មានប្រុសប៉ុន្មាន..?

គ៖ បើគិតតាំងចៅបែកគ្នាចៅប្រាំ...

ខ៖ បើគិតតាំងបែកគ្នា...ប៉ិនណាស់បែកគ្នាអស់ទៅណាស់មួយគេទៅនៅមួយម្ដាយណុងចៅប្រុសដល់ហើយក៏នៅសល់ចៅបួនសុទ្ធតាស្រី

ក៖ ពួកគាត់មានអាយុប៉ុន្មានៗហើយដែរ?

ខ៖ ចៅទីមួយអាយុដប់ប្រាពីរឆ្នាំ ទីពីរអាយុដប់ប្រាំមួយឆ្នាំ ទីបីមានអាយុដប់មួយឆ្នាំ

ខ៖ ចុះកូនអាសាវ៉ាត់អាយុប៉ុន្មាន កូនអាសាវ៉ាត់អ្នាស់និងហើយកូនអាសាវ៉ាត់អាយុដប់ពីរឆ្នាំប្រុសអ្នាស ចៅមួយទៀតនិងប្រាំពីរឆ្នាំ

ក៖ គាត់មានឈ្មោះអីខ្លះអ៊ុំ?

ខ៖ ឈ្មោះពីរនាក់និងឈ្មោះអឺ......លីតាមួយ ឈ្មោះចិន្តាមួយ ហើយឈ្មោះស្រីអៀងមួយ មួយទៀតឈ្មោះស្រីនិច អានីឈ្មោះអីឈ្មោះអឺនេក ចឹង

ក៖ ចាំ ដូចជាចង់សួរអ៊ុំដូចជាអ៊ុំស្រីមានចាំសាច់រឿងខ្លះៗជាមួយនិងបងប្អូនបងស្រីអ្នាសថាធ្លាប់មាន អនុស្សាវរីយ៍អីជាមួយគ្នាកាលពីនៅក្មេងអីចឹងអ្នាសអ៊ុំស្រីធ្លាប់មានទេ?

ខ៖ មានតាស...

ក៖ តើអាចចែកចាយមកកាន់ពួកយើងបានទេថាអ៊ុំបានឆ្លងកាត់អីខ្លះ?

ខ៖ ចាំ (សើច)រឿងបងប្អូនញ៉ុមកាលនៅបលពតខ្ញុំចេញទៅខាងផ្នែកកងចល័តទៅប្អូនៗញ៉ុមគេនៅផ្ទះ ទៅគេបែងចែកអោយក្មេងទៅនៅផ្សេងទៅបែកគ្នាអស់ក៏អត់បាននៅជុំគ្នាទេម្តាយក៏មិនបាន នៅជុំដែរនៅរៀងៗខ្លួនទាំងអស់ ជូនកាលទៅធ្វើការចឹងទៅត្រូវថ្ងៃគេសម្រាកចឹងទៅរត់មកលេងផ្ទះចឹងបាត់បងប្អូនបាត់ម៉ែឪអ ស់ជូនកាលរត់ទៅយំព្រោះរកម៉ែឪក៏មិនឃើញបងប្អូនក៏នៅតាមការដ្ឋានទាំងអស់ចឹងទៅ

ក៖ កាលជំលៀសទៅនិងអ៊ុំជំលៀទៅខាងខេត្តក្រចេះ?

ខ៖ អត់ក្រចេះគេសញ៉ុមនៅខាងកៀនស្វាយនាគពីដំបូងញ៉ុមនៅក្រចេះមែនតែដលពេលឪពុកញ៉ុ មគាត់ស្លាប់និងម្តាយញ៉ុមក៏វិលទៅស្រុកវិញខេត្តស្វាយរៀងអ្នាស នៅជនាន់អាពតនិងទៅដល់ពេលជំនាន់អាពតនិងមកក៏ជំលៀសមកខេត្តកៀនស្វាយនិងម៉ោ

ក៖ ចាំ......!

ខ៖
ដល់ពេលនិងហើយក៏បែកពេញនិងមកពីចិតប្រាំបួននិងម៉ោហើយម៉ែខ្ញុំក៏នាំម៉ែកូនបួននាក់ប្រាំនាក់ម៉ែកូនគាត់មេម៉ាយដែលនោះមករកស៊ីនៅផ្សាដីហុយនិង
រកស៊ីនៅផ្សាដីហុយដឹកបន្លែដឹកអីលក់នៅច្បារអំពៅនិងហើយយូរទៅប្រហែលបានប្រាំប្រាំមួយខែម៉ែញុំក៏ដើររកការងារធ្វើទៅបានចូលនៅក្រសួងគមនាគមន៍ពីរនាក់ខ្ញុំនិងធ្វើការនៅវត្តភ្នំរហូតទៅដល់ពេលដល់ឡើគាត់វិវត្តន៍រហូតតតាគាត់ស្លាប់ទល់តារាល់ថ្ងៃនិងទៅហើយបងប្អូនក៏ទៅបន្តបន្ទាប់ទៅក៏នៅសល់តាបីអ្នកនិងទៅ។

ក៖ ចុះអ៊ុំស្រីនៅបន្តនៅធ្វើការនៅទីនោះទេ?

ខ៖ ខ្ញុំអត់ទេខ្ញុំឈប់យូរហើយ។

ក៖ អ៊ុំឈបធ្វើការប្រហែលជាប៉ុន្មានឆ្នាំហើយ?

ខ៖ ឈប់យូរហើយតាំងពីមួយពាន់ប្រាំបួនរយប៉ែតជាងអួស ប៉ែតជាងហើយញុំមឈប់កាលញ៉ុមនៅឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនមកញ៉ុមធ្វើការនៅវត្តភ្នំនៅក្រសួងគមនាគមន៍និងអាបិងដល់ពេលមកដល់ឆ្នាំប៉ែតសិបមកក៏ឈប់ទៅ។

ក៖
ដូចជាកាលអ៊ុំនៅពីក្មេងអ៊ុំចូលចិតធ្វើអីខ្លះជាមួយពួកគាត់ជាមួយនិងបងប្អូនអ៊ុំអ្ហាសដូចថាអ៊ុំធ្លាប់ធ្វើអីជាមួយគ្នាចឹងអ្ហាសដូចថាធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់អីចឹងអ្ហាអ៊ុំដែលជិតជាប់ក្នុងអារម្មណ៍ចឹងអ្ហ៎?

ខ៖ ព្រោះអីបងប្អូនញ៉ុមអត់សូវបាននៅជុំគ្នាអីចឹងអ្ហាស ព្រោះអីតាំងពីនៅតូចៗញ៉ុមច្រើនណាំបែកពីម្ដាយញ៉ុមដូចថានៅកន្លែងផ្សេងៗធ្វើការអីចឹងអ្ហាសចឹងបានអត់សូវបាននៅជាមួយគ្នាជិតស្និទទេតាំងពីជំនាន់អាពតមកបើមកចិតប្រាំបួនគ្រាន់ថាយើងបានកាលជំនាន់អាពតនិងទៅរកប្អូនស្រីបន្ទាប់ពីញុំនិងធ្លាប់ទៅជិះទូកដកក្រអាវឈូកទៅបឹងទៅដកក្រអាវឈូកទៅដូរអង្ករទៅដូរអីកាលជំនាន់និងជូនកាលទៅញ៉ុមកាលនៅផ្សាដីហុយនិងដើរទៅដល់ផ្សាគគីរអួសទៅដើរអូសរទេះអូសអីទៅទិញបន្លែទិញអីចឹងយកមកអង្គុយលក់ចឹងទៅនៅផ្សាចាស់ផ្សាអីចឹងទៅទំរាំរកបានការងារធ្វើ។

កៈ ចុះម្តាយរបស់អ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខៈ គាត់ឈ្មោះមិន សូវែត។

កៈ គាត់នៅរស់ក៏ស្លាប់ហើយ?

ខៈ គាត់ស្លាប់អស់ហើយ។

កៈ គាត់ស្លាប់នៅជំនាន់ពលពតឬបែកហើយ?

ខៈ អត់តេសបែកអាពតហើយ។

កៈ បែកហើយប្រហែលជាប៉ុន្មានឆ្នាំណាដែរ?

ខៈ អ្ហឺ..គាត់ទើបនិងស្លាប់បានប្រាំខែនិង ចាំគាត់នៅធ្វើការនៅធ្វើអីនិងទល់តាគាត់អាត្រែត

កៈ តើម្តាយរបស់អ៊ុំស្រីកើតនៅឆ្នាំណា?

ខៈ ញ៉ូមអត់ចាំផង។

កៈ កាលគាត់ស្លាប់នេះនៅអាយុប៉ន្មាន?

ខៈ គាត់ស្លាប់នៅអាយុចិតសិបបី។

កៈ ចុះឪពុករបស់អ៊ុំវិញ?

ខៈ ឪពុកខ្ញុំស្លាប់ជំនាន់អាពត...!

កៈ គាត់ឈ្មោះអីគេដែរ?

ខៈ គាត់ឈ្មោះ ឡឹក សំបូរ។

កៈ គាត់ស្លាប់នៅអាយុប៉ុន្មានអ៊ុំ?

ខៈ កាលគាត់ស្លាប់និងហុកជាង ហុកពីរ។

កៈ គាត់ស្លាប់ដោយសារអាពតឬក៏មិចអ៊ុំ?

ខ៖  ស្លាប់នៅជំនាន់អាពតដោយសារជំងឺ គាត់ឈឺដូចថាគ្មានថ្នាំគ្មានអីព្យាបាលអ្ហាស។

ខ៖ឪពុកញ៉ុមគាត់ធ្វើការដល់ពេលទៅជំនាន់អាពតនិងទៅមានថ្នាំណាមើលដូចយើងកាលមុន ។

ក៖  ចាំ...!

ខ៖  ចឹងបានគាត់ស្លាប់និង។

ក៖  ប៉ារបស់អ៊ុំកើតនៅខាងណាវិញអ៊ុំ ដចថាទីកន្លែងកំណើតគាត់អ្ហាំស?

ខ៖  ទីកន្លែងកំណើតគាត់នៅងស្វាយរៀងនិងអូន។

ក៖  គាត់កើតនៅស្វាយរៀងទាំងពីរនាក់?

ខ៖  ចាំ...!

ក៖  គាត់ជា...ដូចថាប្រកបរបរអីចិញ្ចឹមជីវិតដែរម្ដាយរបស់អ៊ុំអ្ហាស?

ខ៖ អីម្ដាយញ៉ុមកាលដើមឡើយគាត់ជាអ្នកធ្វើស្រែនិង...ចាំជាកូនកសិករនិងដល់ពេលឪពុកញ៉ុម គាត់ធ្វើការនៅរោងចក្រនៅឆ្លងក្រចេះអ្ហស។

ក៖  ចាំ...ទៅគាត់ជួបគ្នា..?

ខ៖ ចាំ...ប៉ិនព្រោះស្រុកកំណើតគាត់នៅទីនោះដែលទើបបានជួបគ្នានុង ក៏គាត់បានរៀបចំគូស្រករហើយក៏គាត់ទៅអីឆ្លងក្រចេះទាំងអស់គ្នាចឹងអ្ហាសបានជាបងប្អូនញ៉ុមកើតនៅនុងទាំងអស់ចឹងទៅ។

ក៖  ចាំ...ចុះអ៊ុំគិតថាគាត់គឺជាមនុស្សបែបណាដែល ទាំងម្ដាយទាំងឪពុក?

ខ៖  គាត់មានអី..មនុស្សគាត់ហ៊ីដូចថាគាត់រស់នៅក្នុងគ្រួសារគឺគាត់រក្សាកូនចៅ។

ក៖  អ៊ំ...!

ខ៖ ចាំ គាត់រក្សាកូនចៅបានល្អណាស់គាត់មិនដែលអោយកូនចៅពិបាកទេក្លាយកូនចៅអត់ក្លាយកូនចៅវេទនាខំប្រឹងរកស៊ីគ្មានពេលសំរាកម្តាយខ្ញុំដល់ចុងបញ្ចប់គាត់ស្លាប់ទៅមានអីបន្សល់ទុកអោយកូនទាំងអស់។

ក៖ ចាំ...! គាត់ល្អមែនទែន

ខ៖ ចាំ...!

ក៖ ចុះអ៊ុំស្រីស្រលាញ់គាត់ខ្លាំងទេ...?

ខ៖ ស្រលាញ់...! ហាសហាសហា...។

ក៖ បើគាត់បានលឺគាត់ច្បាស់ជាសប្បាយចិត្តខ្លាំណាស់.. អ៊ុំមានបានចងចាំសាច់រឿងជាមួយនិងគាត់ទេ ដូចថាធ្លាប់ទៅរកត្រីឫក៏ទៅធ្វើស្រែជាមួយគ្នា?

ខ៖ អុំ ពីរនាក់ម្តាយញ៉ុមអ្នាស

ក៖ ចាំ បានធ្វើអីខ្លះជាមួយគ្នា...?

ខ៖ អ្វី ប្រវត្តិញ៉ុមមួយម្តាយញ៉ុមនេះអ្នាសតាំងពីជំនាន់អាពតម៉ោឃើញម្តាយទូចពេកដែលអាជិញគេជំលៀសទៅមិនអោយដើរគាត់រែកកូនអ្នាសដាក់សង្រែករែកកូនម្ខាងមួយម្ខាងមួយ ហាសហាសហា។

ក៖ ដូចលក់នំបញ្ចុកអញ្ជឹងហាសហាសហា..?

ខ៖ និងហើយ...! រែកកូនម្ខាងមួយលើក្បាលទូលឥវ៉ាន់ទៀតហើយខ្ញុំបងគេធម្មតាចេះតាទូលតាមក្រោយគាត់ទៅហើយគាត់ខំប្រឹងរែកកូនដើរម៉ោដល់អ្នកលឿងដើរម៉ោកណ្តាលថ្នល់ហាលភ្លៀងហាលអីសើមក៏មានអីក៏មានហ៊ឺហ៊ឺសកំសត់ណាស់។

ក៖
ចុះគាត់ធ្លាប់ប្រាប់អ៊ុំអំពីខ្សែជីវិតរបស់គាត់ដូចថាគាត់ធ្លាប់ស្ថិតនៅក្នុងស្ថានភាពបែបណានៅពេលនៅជាមួយគ្នាដូចថាគាត់ធ្លាប់ប្រាប់ថាអកម៉ាក់ពីក្មេងគាត់ធ្លាប់ធ្វើនេះធ្វើនោះចឹងអ្នា?

ខ៖ គាត់ធ្លាប់ធ្វើស្រែធ្វើអីគាត់ថាគាត់ធ្វើការដូចក្របីដូចគោចឹងគាត់មនុស្សមែនប៉ុន្តែគាត់មិនដែលខ្ជិលទេគាត់ភ្ជួរស្រែដូចមនុស្សប្រុស(សើច)គាត់លីនង្គ័លគាត់មាឌគាត់ធំអ្នាសគាត់លីនង្គ័លទៅភ្ជួរទៅអីចុះគាត់កំព្រាម្តាយតាំងពីគាត់អាយុប្រាំពីរឆ្នាំតាំងពីអាយុប្រាំពីរឆ្នាំដល់ពេលហើយគាត់រស់នៅជាមួយឪពុកគាត់គាត់មកខំធ្វើស្រែទាំងឪពុកទាំងកូនគាត់និយាយប្រវត្តិគាត់។

ក៖ ពេលដែលអ៊ុំបានដឹងអំពីជីវប្រវត្តិគាត់តើអ៊ុំមានអារម្មណ៍បែបណាទៅ?

ខ៖
ញ៉ុមចេះតានឹកឃើញស្តាយស្រណោះនឹកគាត់ដូចថានឹកអាណិតគាតអ្នាសគាត់ខំប្រឹងព្យាយាមខំប្រឹងរកស៊ីចិញ្ចឹមកូនម៉ោដែលលំបាកវេទនាបំផុតកំសត់អ្នាសអាណិតគាត់ដែលស្តាយគាត់ព្រោះគាត់ខំប្រឹងទុកអោយកូនបានហូបចុកអីអត់ហ៊ានហូបអីពរញលេញចឹង។

ក៖
បើសិនញ៉ុមជាចៅរបស់អ៊ុំញ៉ុមនិងមានអារម្មណ៍រំភើបជាងនេះទៀតបើបានលឺដូចជាបានដឹងអំពីដូចជាលោកយាយចឹងអ្នាស?

ខ៖ ចា៎...!

ក៖ ចុះយាយតារបស់អ៊ុំវិញទាំងយាយតាខាងម្តាយតើមានឈ្មោះអ្វីខ្លះទៅ?

ខ៖ ញ៉ុមអត់បានឃើញមុខគាត់ផងញ៉ុមពេលញ៉ុមកើតឡើងអត់បានឃើញយាយញ៉ុមផងយាយហើយប៉ាបង្កើតរបស់ខ្លួនឯងផង។

ក៖ ចុះមានបានស្គាល់ឈ្មោះគាត់ទេអ៊ុំ?

ខ៖ ស្គាល់...!

ក៖ ចា៎ យាយតាខាងម្តាយឈ្មោះអីដែរ?

ខ៖ គេហៅតាសំ យាយម៉ែ...។

ក៖ យាយម៉ែ...?

ខ៖ ចា៎..!

ក៖ អ៊ុំស្រី....! ញ៉ុមមានយាយម្នាក់ឈ្មោះយាយម៉ែដែរ គាត់ឈ្មោះយាយម៉ែ ហើយម៉ែជាឈ្មោះរបស់គាត់គឺម៉ែ គាត់ស្លាប់ជំនាន់អាពត?

ខ៖ អ៎...មែនទេគាត់ស្លាប់តាំងពីញ៉ុមមិនទាន់កើតមិះនិង។

ក៖ អ៎....តែឈ្មោះដូចគ្នាហាសហាសហា(សើច)ញ៉ុមខំភ្ញាក់ផ្អើលស្មានតាតែមួយ?

ខ៖ ញ៉ុមមិនទាន់កើត ថាទៅនិយាយរួមទាំងយាយទាំងតាញ៉ុមកើតអត់ទាន់ទាំងពីរនិង ញ៉ុមនៅទូចពេកហើយម្ដាយញ៉ុមកំព្រាតាំងពីអាយុប្រាំពីរឆ្នាំណោះនិង។

ក៖ ចុះយាយតាខាងឪពុកវិញ?

ខ៖ ខាងឪពុកក៏ញ៉ុមអត់ដឹងដេស។

ក៖ចា៎..ចុះអ៊ុំស្គាល់ឈ្មោះគេទេ?

ខ៖ អត់ស្គាល់ទេខាងឪពុក ព្រោះឆ្ងាយ។

ក៖ តើអ៊ុំដឹងថាយាយតាខាងម្ដាយគាត់ស្លាប់ដោយសារអីទេអ៊ុំ?

ខ៖ គាត់រល់តាឈឺ បើតាគាត់រល់តាឈៃចាស់ហា៎សហើយបើយាយវិញគាត់ឈឺពេលនិងគាតឈឺអីទេ...តែញ៉ុម លឺគាត់និយាយថាគាត់ខ្យល់គរអីចឹងអ្ហាសដល់ពេលតាញ៉ុមគាត់ ឈឺជំងឺគាត់ចឹងហា៎សគាត់អាយុប៉ែតជាងអួសទើបគាត់ស្លាប់តែញ៉ុមកើតអត់ទាន់បានឃើញមុខគាត់ផងនិងញ៉ុមដឹងតាប៉ុននិង។

ក៖ តែម្ដាយរបស់អ៊ុំស្រីធ្លាប់និយាយរឿងទាក់ទងនិងយាយតាអោយស្ដាប់ទេ?

ខ៖
គាត់អត់សូវបាននិយាយរឿងអីប្រាប់ញ៉ុមច្រើនទេព្រោះអីម្ដាយញ៉ុមគាត់អាយុប្រាំពីរឆ្នាំម្ដាយគាត់ស្លាប់ហើយនិង។

ក៖ អញ្ចឹងគាត់អត់សូវបានដឹងរឿងអី...?

ខ៖ គាត់អត់ដឹងទេព្រោះគាត់នៅក្មេងដែរទៃគាត់នៅជាមួយឪពុកគាត់ គាត់ធ្វើស្រែពីរនាក់ឪពុកគាត់ហើយបងបងការហើយចេញអស់ និងគាត់ធ្លាប់ឧស្សាហ៍និយាយប្រាប់ប្រវត្តិប៉ុននិង។

ក៖ ឥលូវចូលដល់រឿងស្វាមីអ្នកមីងវិញម្ដងតើស្វាមីរបស់អ្នកមីងឈ្មោះអីដែរ?

ខ៖ គាត់ឈ្មោះជុំ សារិម។

ក៖ ជុំ សារិម គាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់អាយុហុកប។

ក៖ គាត់អាយុហុកបី គាត់កើតនៅឆ្នាំណាអ៊ុំចាំទេ?

ខ៖ អូយអ៊ុំអត់ចាំទេអ្នា។

ក៖ ចាំ...អត់អីទេ?

ក៖ ចុះគាត់រកស៊ីមុខរបរអីដែរ?

ខ៖ គាត់ធ្វើការ។

ក៖ គាត់ធ្វើការអីអាចប្រាប់បានទេ?

ខ៖ គាត់ធ្វើការខាងយោលធា។

ក៖ គាត់ជាយោលធា ...! វ៉ាវឡូយមែន?

ក៖ ចុះអ៊ុំស្រីនិងអ៊ុំប្រុសជួបគ្នានៅទីណាដែរ?

ខ៖
ជួបគ្នានៅភ្នំពេញនិងដែរប៉ិនតាគាត់នៅខាងកំពង់ស្ពឺគេអ្នកកំពង់ស្ពឺតែឪពុកជាអ្នករៀបចំអោយហើយឪពុកម្ដាយខាងគាត់ត្រូវជាសាច់ញ្ញាតិខាងម្ដាយញ៉ុមដែរនិងអ្នាសប្រវត្តិដើមម៉ោរួចហើយចាស់ចាស់ចេះតាផ្សំផ្គុំអោយទៅ។

ក៖ ប៉ុន្តែអ៊ុំក៏ស្រលាញ់ខ្លួនដែរ ហិកហាសហាសហា....! ?

ក៖ តែអ៊ុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍មានហៃរជំនុនតាមប្រពៃណីតាអ្វីអ៊ុំ?

ខ៖ ចាំ...ជំនាន់និងញ៉ុមការ ញ៉ុមនៅធ្វើការដែរ អ្ហេសជំនាន់ការនិងនៅខែដប់ឆ្នាំចិតប្រាំបួនជិតប្រាំបួនខែដប់។

ក៖ ចាំ...!

ខ៖ កាលនោះខែដប់ កាលណុងនៅចាយអង្គអ្នាសនៅចាយអង្ករដល់ពេលយើងអ្នកហៅភ្ញៀវហៅអីចឹង ជូនកាលគេយកតាអង្ករមកចងដៃអ្នកខ្លះចងសាច់គេជួយអីចឹងទៅ។

ក៖ ដូចសប្បាយជាងណាំអ៊ុំ?

ខ៖ ចាំ...សប្បាយ...! ។

ក៖ ព្រោះឥលូវយើងចាយលុយយើងក្លាយតែខាត តែនេះយើងបានរបស់មកវិញចឹងអ្នាស?

ខ៖ ចាំ..........! ។

ក៖ តើនៅពេលអាពាហ៍ពិពាហ៍របស់អ៊ុំស្រី តើអ៊ុំស្រីមានអារម្មណ៍យ៉ាងមិចដែរ?

ខ៖ មានអីតេសអត់ចង់ដែល ថាទៅធម្មតា។

ក៖ ហីអ៊ុំកុហកញ៉ុមហើយ

ខ៖ ហាសហាសហាំ.....! ។

ក៖ ពេលនិងច្បាស់ជារំភើបហើយ?

ក៖ តើដូចជាស្វាមីរបស់អ៊ុំស្រីជាមនុស្សបែបណា ដូចថាគាត់មានចរិតលក្ខណៈបែបណា?

ខ៖ ហ៎្អ...មានអីទេចរិតលក្ខណៈរបស់គាត់ល្អគុណសម្បត្តិល្អ

ក៖ចំណុចអីដែលអ៊ុំស្រលាញ់គាត់ជាងគេ ចំណុចដែរស្រលាញ់ជាងគេអ្វ៉ាអ៊ុំ។

ខ៖ស្រលាញ់ចំណុចអីធម្មតាដូច
ថាទៅណាម៉ោណាអីចេះគិតគូរប្រពន្ធកូនអីចឹងអ្ហាសអោយតាមានអីចឹងយកមកផ្ញើប្រពន្ធកូនទៅដល់ណាក៏ដោយបើមិនបានទិញផ្ញើអ្នកផ្ទះអត់អស់ចិត្តទេ។

ក៖
ចា៎...ល្អមែនទែនចា៎អ៊ុំស្រីយើងបង្វែរឿងវិញតើអ៊ុំស្រីចេះសរសេរចេះអានភាសាខ្មែរច្បាស់ទេ?

ខ៖ ញ៉ុមអត់សូវប៉ុន្មានទេព្រោះអីជំនាន់និងញ៉ុមអត់សូវបានរៀនខ្ពង់ខ្ពស់។

ក៖ សុំទោសអ៊ុំតើអ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ អូយ...! ញ៉ុមរៀនបានថ្នាក់ទាបណាស់អូន ជំនាន់ណុង។

ក៖ អ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖
ជំនាន់និងរៀនបានថ្នាក់ទីពីរយើងពីសង្គមរៀនហើយសង្គ្រាមពេលរៀនសង្គ្រាមម៉ោរត់រហូតគ្មានបានរៀនជាប់ទេដល់ពេលមកដល់ជំនាន់អាពតនិងទៀតបាត់ឆឹងប៉ាដោយ។

ក៖ ចា៎....! តែអ៊ុំអាចមើលដាច់ទេ?

ខ៖ ចា៎ អាចមើលទៅរួចអានដាច់ប៉ុន្តែសរសេរ សរសេរអត់សូវទេ។

ក៖ ចុះអ៊ុំចេះភាសាអីផ្សេងទេ?

ខ៖ អត់ចេះផង...

ក៖ ចា៎ដូចជាកាលអ៊ុំរៀនអ៊ុំរៀនសាលាណាដែរ?

ខ៖ អូយញ៉ុមអត់ចាំទេពេលនិងរៀននៅឆ្លូងក្រចេះណាស់។

កៈ ចាំ...កាលនិងរៀនថ្នាក់ទីប៉ុន្មានអ៊ុំ អ៊ុំប្រាប់ញ៉ុមនៅ?

ខៈ ថ្នាក់ទីពីរ....! កាលនិងទើបតែអាយុដប់ឆ្នាំរៀននិងហើយពេលនិងរៀនថ្នាក់ទីពីរ។

កៈ អ៊ុំមានមិត្តភក្រ្តនៅសាលានោះទេអ៊ុំ?

ខៈ អូយ...! ភ្លេចអស់ហើយអ្ហាអាព្រោះយូរហើយ។

កៈ ចាំ ព្រោះយូរឆ្នាំហើយតាំងពីប៉ុន្មាបឆ្នាំមុន?

ខៈ នេះបើដើរបុកគ្នាអីអាចស្គាល់គាត់ទេ។

ខៈ អូ...! អត់ស្គាល់តេស។

កៈ អ៎...! ព្រោះនៅទូចទូចពេក?

ខៈ ចាំ នៅតូចតូច...។

កៈ មានអីជិតដាមក្នុងអារម្មណ៍អ៊ុំទេដូចថារសជាតិខុសពីឥលូវអីចឹងអ្ហាអ៊ុំថាពីមុនសប្បាយបែបផ្សេងអីចឹងអ្ហាស?

ខៈ ពីក្មេង...អ្ហឺដូចជាភ្លេចអស់ហើយអ៊ុំភ្លេចអស់ហើយអូន។

កៈ ចុះអ៊ុំចូលចិត្តលេងកៅស៊ូអ្ហេស?

ខៈ អ៊ុំចូលចិត្តលេង...តាសហាក់កៅស៊ូលោតអន្ទាក់អីចឹងទៅជូនកាលនាំគ្នាលេងលាក់កន្សែងលាក់អីចឹងអ្ហាសពេលមានបុណ្យទានម្តងម្តងកាលនៅក្មេងៗនិងពិសេសជាងគេលេងលោតកៅស៊ូនិងម៉ង លោតកៅស៊ូលោតកំពស់និងកាលជំនាន់នៅក្មេងក្មេងនិង។

កៈ ចាំ...!

ខៈ ដល់ហើយពេលយើងមានសង្រ្គាមនិងក៏នាំគ្នាបែកខ្ញែកគ្នាអស់កាលម៉ឺកជំនាន់អាដេញកាប៉ា

ល់ហោះទម្លាក់
នាក់រោងចក្រនិងនាំគ្នារត់អាប៉ាត់អាប៉ាយអស់ទៅៗនៅស្រុកនោះឆ្ងាយៗចឹងបែកគ្នាអស់ទៅ។

ក៖
ចុះអ៊ុំបានធ្លាប់ធ្វើការងារអីខ្លះតាំពីអ៊ុំដឹងក្ដីរហូតដល់អ៊ុំចាស់ចំណាស់នេះអ្នាសអ៊ុំកាលនិងអ៊ុំធ្លាប់ឆ្លងកាត់ការងារអីគេខ្លះ?

ខ៖
ខ្ញុំកាលនិងរត់ទៅនៅស្រុកចំការចេញពីខេត្តឆ្លងនោះញ៉ុមទៅឯខាងស្រុកចំការគេនិងញ៉ុមដូចថាទៅតានេះរៀនបន្តិចទៅតានោះរៀនបន្តិចចេះតាចូលរៀនចឹងហាសដល់ពេលទៅរៀនចឹងពេលចេញពីររៀនទៅជួនកាលទៅរើសផ្លែគរ
ជួនកាលទៅកាច់សន្លឹកថ្នាំលក់អោយគេមួយកញ្ចេប្អូនប្រាំរៀលចឹងទៅ។

ក៖ វ៉ាវ...!
ជួនកាលម៉ែញ៉ុមប្រើញ៉ុមអោយដើរលក់ចឹងទៅនិងហើយតាំងពីដាំថ្នាំកាច់ពោតកាច់អីនិយាយរួមកាច់ធ្វើម៉ាចប់អីក៏ខ្ញុំធ្វើដែរ(សើច)កាលនៅក្មេងអត់ដែលចេះនៅទំនេរហើយថាចេះតានេះម៉ាជប់តានោះម៉ាជប់ហើយអត់មានចេះចប់ហ៎?

ក៖
អ៊ុំស្រីគួរអោយស្រលាញ់មែនទែនហើយចុះតើដូចជាល្បែងប្រជាព្រៃអីខ្លះដែរអ៊ុំចូលចិត្តអ្នាសដូចថានៅពីក្មេងក៏ដោយឬក៏ឥលូវនិងក៏ដោយល្បែងអីដែរអ៊ុំដូចថាក្នុងចិត្តរបស់អ៊ុំចង់លេងជាងគេអ្នាស ដូចជានៅពីក្មេងចូលចិត្តលេងហាក់កៅស៊ូចឹងអ្នាស?

ខ៖ ចា៎ ពីមុនចូលចិត្តហាក់កៅស៊ូតែឥលូវមិនដឹងចូលចិត្តស្អីទេអ្នាស។

ក៖ ចុះអ៊ុំចូលចិត្តចំរៀងទេ?

ខ៖ អត់សូវដែរជួនកាលទំនេរដេកស្ដាប់ចឹងទៅ។

ក៖ ញ៉ុមរកច្រៀងអោយអ៊ុំស្ដាប់តែលូវអ៊ុំថាអត់ចូលចិត្តចឹងចប់បណ្ដោយ?

ខ៖ អត់ទេបើចង់អោយច្រៀងយើងច្រៀងអោយស្ដាប់អញ្ចេក។

ខ៖  តែបើប្រលងចំរៀងអីចឹងចូលចិត្តមើលតាស។

ក៖ វ៉ាវ...! អ៊ុំចាំញ៉ុមចប់ចាំមើលអ៊ុំពេលញ៉ុមចប់ញ៉ុមមករកអ៊ុំហើយអោយច្រៀងអោយស្តាប់?

ក៖  ចុះអ៊ុំចូលចិត្តពណ៌អីដែរ?

ខ៖  ពណ៌..! ញ៉ុមចូលចិត្តពណ៌កំបោរ។

ក៖  ពណ៌កំបោរ ប្លែកអ៊ុំពណ៌កំបោរ ព្រោះអត់សូវដែរឃើញ?

ក៖  ចឹងតាំងពីក្មេងមកអ៊ុំចូលចិត្តដូចជាស្អីគេអញ្ចេះ អំចាំឥលូវនិងម៉ងអ៊ុំចូលចិត្តចម្រៀងបុរាណឬក៏សម័យ?

ខ៖  ចូលចិត្តបុរាណ។

ក៖  អំ...ចូលចិត្តបុរាណជាងសម័យ?

ខ៖  ចាំញ៉ុមចូលចិត្តបុរាណជាង។

ក៖  តើគ្រួសារអ៊ុំឬក៏អ៊ុំចេះលេងភ្លេងខ្មែរទេ?

ខ៖  អូយញ៉ុមអត់ចេះទេញ៉ុមអត់អ្នកចេះលេងផងប៉ុនណាចូលចិត្តស្តាប់នេះចឹងម៉ង។

ក៖  ចុះកាលពីនៅក្រចេះអ្នាអ៊ុំស្ថានភាពផ្ទះអ៊ុំយ៉ាងណាដែរផ្ទះឈើផ្ទះថ្មអីចឹងញ៉ុមចង់អោយអ៊ុំស្រមៃមើលថាស្ថានភាពផ្ទះអ៊ុំកាលនៅក្រចេះកាលនៅពីក្មេងធ្វើស្រែជាមួយគ្នានិងស្ថានភាពផ្ទះបែបណាដែរ?

ខ៖  ញ៉ុមផ្ទះឈើ។

ក៖  ឈើ...អ៊ុំចុះប្រក់អ៊ុំផ្ទះអ៊ុំប្រក់អី?

ខ៖  កាលនិងប្រក់ពីដើមប្រក់អាស៊ីប្រូនិង។

ក៖  ចុះទេសភាពជុំវិញផ្ទះវិញ?

ខ៖
ជុំវិញផ្ទះមានអីតេសជូនកាលមើលទៅឃើញស្រូវដំណាំចំការដូចជាអំពៅដូងចេកអូចឹងទៅ។

ក៖ គ្រាន់តាស្តាប់លឺមានអារម្មណ៍ចង់បេះបាត់ហើយអត់ទាន់បានទៅដល់ហ៎ង.... ចុះចឹងផ្ទះនិងសាងសង់ឡើងដោយខ្លួនឯងក៏យាយតាឬក៏ម៉ាក់អ៊ុំជួលគេមកសង់?

ខ៖ ឪពុកម្តាយញ៉ុមអ្នកជួលគេមកសាងសង់។

ក៖ អ..តើអ៊ុំស្រលាញ់ផ្ទះនោះទេ?

ខ៖
ញ៉ុមស្រលាញ់ដល់ពេលឥលូវញ៉ុមទៅរកផ្ទះនិងអត់ឃើញវាបាត់អស់អាលីងមិនដឹងទៅដល់ណាខ្លះ។

ក៖ តែមានអនុស្សាវរីយ៍ច្រើនជាមួយផ្ទះនោះទេ?

ខ៖ មានច្រើនតែ....បើត្រលប់ទៅវិញក៏រកមិនឃើញដែរបើបាត់ស្រម៉ោអស់ហើយ។

ក៖ ចុះតើអ៊ុំមានបញ្ហាក្នុងជីវិតទេ?

ខ៖ ញ៉ុមឥលូវរាល់ថ្ងៃនិងញ៉ុមអត់ទេ។

ក៖ តែពីដើមមក?

ខ៖ ចា៎...ពីដើមញ៉ុមអត់មានបញ្ហាអីតេស ញ៉ុមអត់អីទេគ្រាន់តែញ៉ុមកំសត់កំព្រាឪពុកម្តាយនឹកឃើញដូចថាស្រណោះគាតអ្នាស គាត់ខំប្រឹងទុកអោយកូនទុកបំរុងអោយកូនចៅកុំអោយកូនចៅពិបាក ចា៎ចុងបញ្ចប់គាត់ទៅអស់អាលីង។

ក៖ អ៊ុំឆ្លងកាត់រឿងអីខ្លះ កាលពីនៅក្មេងម៉ោអ្នាស?

ខ៖
កាលពីនៅក្មេងនិងខំប្រឹងរកពីរនាក់ម្តាយកូនតាំងពីចិតប្រាំបួនម៉ោតាំងពីជំនាន់អាពតបែកភ្លាមម៉ោវាលំបាកខ្លាំង។

គ៖ គ្រាន់តាដឹងថាពិបាកមិនអាចនិយាយបានអ្នាស

ខ៖ ហើយបើដើរអ្នាសដើរមែនជិតណាអូន ដើរអូសអាទាសពីភ្នំពេញទៅអឺស ពីមួយរយខ្ទងទៅកៀនស្វាយអ្នាសទៅទិញបន្លែម៉ោហើយនៅអូសម៉ោទៀតអ្នាសពីរនាក់ម្ដាយកូនមែនជិតណា។

ក៖ ជើងសង្ស័យឡើងសាច់ដុំពិនយក្សហើយមើលទៅ?

ខ៖ និងហើយ...!

ក៖ តែអ៊ុំនៅតែស៊ូទ្រាំធ្វើវាបាន?

ខ៖ ចា៎..! ញ៉ុមនៅតែស៊ូទ្រាំ។

ក៖ តើមូលហេតុអីបានជាអ៊ុំនៅតែស៊ូទ្រាំធ្វើវាបាន?

ខ៖ ដោយសារក្ដីស្រលាញ់....!

ក៖
ចា៎..!ដោយសារក្ដីស្រលាញ់ក្នុងគ្រួសារចិញ្ចឹមកូនចិញ្ចឹមអីគាត់និងទម្រាំនេះអ្នាសទម្រាំគាត់រកការងារបានធ្វើបក៏បានធូរ
ចា..បានកូនចៅទៅរៀនទៅសូត្រអីចឹងទៅចេះតាឡើងនេះទៅរហូតទៅ?

ក៖ ចា៎...! តើអ៊ុំមានបទពិសោធន៍អីល្អល្អចង់ចែកចាយមកកាន់ពួកយើងទេអ៊ុំ ដូចថាភាពតស៊ូរបស់អ៊ុំថាអ៊ុំបានអញ្ចេកៗចឹងអ្នាសអ៊ុំ
ឬក៏យ៉ាងណាដូចជាភាពក្លាហានដែលអ៊ុំមានហើយចងចែកចាយមកកាន់យើងអ្នាស?

ខ៖ តាំងពីខ្ញុំបែកមានគ្រួសារម៉ោអ្អេស។

ក៖
ចាវាបានបង្រៀនអ៊ុំអ្វីខ្លះក្នុងជីវិតរបស់អ៊ុំដែលអ៊ុំចង់ចែកចាយមកកាន់យើងអោយយើងអាចបណ្ដុះគំនិតចឹងនិងណាអ៊ុំ?

ខ៖ អូ..! ចាំពីដើមមកញ៉ុមចាប់ដៃគ្នាប្ដីប្រពន្ធម៉ោមករស់នៅដោយខ្លួនញ៉ុមមុនដំបូងខ្ញុំចិញ្ចឹមជ្រូកម្ដងមួយពីរមួយពីរចឹងទៅញ៉ុមចេះតាទុកមេចឹងទៅញ៉ុមចិញ្ចឹមម្ដងដប់
ម្ដងដប់ម្ដងម្ភៃអីចឹងទៅហើយដល់ពេលហើយវាធំធាត់ចឹងទៅក៏ខ្ញុំបានលក់សល់លុយសល់កាក់ក៏ខ្ញុំ
ចាប់ផ្ដើមញ៉ុមធ្វើម៉ាស៊ីនទឹកកកញ៉ុមធ្វើទឹកកកអីម្នាក់ឯងអីម្នាក់ឯងទៅព្រោះគ្រួសារញ៉ុមគាត់ណាកចុះទៅសមភូមិទៅនៅបាត់ដំបងក៏ខ្ញុំនៅម្នាក់ឯងក៏ខ្ញុំរកស៊ីចិញ្ចឹមកូនរហូត...។

ក៖ អូយ...! ញ៉ុមស្ដាប់រឿងអ៊ុំស្រីជាមនុស្សស្រីរឹងមាំមែនទែនញ៉ុមស្រលាញ់ភាពរឹងមាំរបស់អ៊ុំមែនទែនបើទោះជាអ៊ុំឆ្លងកាត់រឿងលំបាកក៏អ៊ុំអាចធ្វើវាបាន
អាចពុះឆ្លងកាត់រឿងនិងបានអានិងវាអស្ចារ្យមែនទែនអ៊ុំដូចជានៅពីក្មេងអ៊ុំធ្លាប់សង្ឃឹមចង់ធ្វើជាអីទេអ៊ុំ?

ខ៖
ពីក្មេងចេះតាចង់បានអ្នាសតែលទ្ធផលដែលយើងទៅអត់រួចព្រោះយើងអត់បានរៀនសូត្រខ្ពង់ខ្ពស់។

ក៖អត់ទេអ៊ុំឥលូវនិងអ៊ុំប្រាប់ក្ដីស្រមៃដល់ញ៉ុមអោយអស់ពេលខ្លះអ្នាសកូនរបស់អ៊ុំជាអ្នកសម្រេចវាក៏ថាបានដែរ អ៊ុំចង់បានអីខ្លះដូចថាក្ដីស្រមៃអ៊ុំណាស់អ៊ុំចង់បានអីខ្លះ?

ខ៖ រាល់ថ្ងៃក្ដីស្រមៃញ៉ុមរាល់ថ្ងៃដែលថាខ្លួនចាស់ហើយនេះគឺថាចង់អោយតាកូនកូនមានដំរិះវិជ្ជាអីតទៅមុខទៀតតាប៊ិននិងទេចាំអោយវាខំប្រឹងរៀនសូត្រដូចថៅអីចឹងហាសណាស់អោយខំប្រឹងរៀនសូត្រទៅអោយបានតស៊ូជំនាញអីមួយច្បាស់លាស់ចឹងហាសកុំអោយតាតានេះម៉ាចុបតានេះម៉ាចុបចឹងវាអត់ល្អអត់ពិតប្រាកដវាពិបាកណាស់។

ក៖ ចាំហើយចេះស្រលាញ់គ្នាទៅវិញទៅមក?

ខ៖ ចាំ ..! ហើយយើងរកស៊ីដូចសព្វថ្ងៃវាលំបាកណាអោយរៀនសូត្រអោយចេះដឹងទៅមានការងារធ្វើទៅក៏វាថូអីចឹងទៅព្រោះរបស់វា។

កៈ  កាលអ៊ុំនៅក្មេងអ្នាសអ៊ុំស្រមៃចង់ក្លាយទៅជាអីគេអ៊ុំដូចជាការងារអីចឹងអ្នាសអ៊ុំ..?

ខៈ កាលនិងញ៉ុមស្រលាញ់ការងារខាងពេទ្យ តែញ៉ុមនឹកឃើញកាលនោះញ៉ុមចង់ណាស់ចង់ចេះដំរិះវិជ្ជាពេទ្យតែយើងរៀនវាមិនបានខ្ពង់ខ្ពស់អត់បានជិតដល់ព្រោះខ្ញុំវាអាក់ដំណើររបស់ខ្ញុំទៅ។

កៈ  អត់អីទេអ៊ុំ...!

ខៈ ជំហានទីមួយគេហៅញ៉ុមចូលធ្វើជាពេទ្យកាលជំនាន់ប៉ែតជាងអ្នាអូនដល់ពេលហើយញ៉ុមដឹកឃើញថាខ្លួនយើងវាអត់ចេះអីខ្ពង់ខ្ពស់ម្លោះហើយអត់ហ៊ានទៅវិញស្តាយអ្នាសបើញ៉ុមកាលនិង។

កៈ ញ៉ុមគិតថាកូនអ៊ុំនិងអាចសម្រេចវាបាន តើអ៊ុំសង្ឃឹមថាកូនអ៊ុំនិងអាចសម្រេចវាបានអត់ឬក៏ថៅអ៊ុំបើថាអ៊ុំគិតថាកូនមិនបាននៅថៅទៀតថៅទូតថៅលួតថៅលាបើពួកគាត់បានលីសម្លេងអ៊ុំគាត់បានដឹងពីគោលបំណងរបស់ម្តាយរបស់គាត់ចឹងអ្នាស?

ខៈ ញ៉ុមបំរុងគិតគួរអោយនេះដែរតែដល់ពេលចិត្តរបស់គេគេចង់រៀនសាលាច្បាប់ហាសហាសគេថាគេប្រលងជាប់ទីដប់ពីរចឹងទៅគេចង់រៀនសាលាច្បាប់អីចឹងទៅអ្នាស។

កៈ  ចា...! តែអ៊ុំនៅតែស្រលាញ់និងគោរពរាល់ការសម្រេចចិត្តរបស់ពួកគាត់ចឹងអ្នាស?

ខៈ  ចាំ ចាំ..! តាមបំណងរបស់គេចឹងទៅ។

កៈ  អ៊ុំស្រីជាស្រ្តីល្អម្នាក់ជាភរិយាល្អម្នាក់...!

ខៈ ចេះតាខំប្រឹងទៅ ចេះតាបេះបោចអោយគាត់អោយថៅតស៊ូរៀនចឹងទៅមើលតាម៉ែឪគាត់មើលទៅអត់រួចចឹងអ្នាសយាយចេះតាជួយចឹងទៅ។

កៈ ក្តីស្រលាញ់របស់អ៊ុំធំធេង ពួកយើងអរគុណដែរអ៊ុំបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីពួកយើងអាចសម្ភាសន៍អ៊ុំទាក់ទងទៅនិងជីវប្រវត្តិរបស់អ៊ុំចឹងអ្នាសហើយញ៉ុមសង្ឃឹមថានិងមានចៅឬក៏កូនរបស់អ៊ុំបានស្តាប់លឺនូវសម្លេងទាំងអស់នេះចេញពីចិត្តរបស់អ៊ុំពិត

ចេញពីសម្តីរបស់អ៊ុំពិតដែលអ៊ុំចង់ប្រាប់ទៅកាន់ពួកគេផងដែរហើយពួកយើងមានតាប៊ុននិងហើយពួកយើងសូមអរគុណហើយអ៊ឺយយើងសុំអនុញ្ញាតពីអ៊ុំដើម្បីពួកយើងអាចបញ្ចូលសម្លេងអ៊ុំដើម្បីចូលទៅក្នុងវេបផ្សាយរបស់យើងដើម្បីអោយចៅឬក៏កូនរបស់អ៊ុំអាចស្តាប់លឺសម្លេងនិងបានហើយពួកយើងនិងមានឪសសម្រាប់អ៊ុំផងដែរហើយពួកយើងមានតាប៊ីននិងហើយពួកយើងសូមជំរាបលាផងដែរ។

ខៈ ចាំ ចាំ..! អរគុណអូន។

កៈ អរគុណច្រើនអ៊ុំ ឆ្លើយអ៊ុំថាអឺអ៊ុំអត់សូវចេះនិយាយទេក្មួយ..!